មជ្ឈមណ្ឌលឯកសារកម្ពុជា

# កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្លេងយុត្តិធម៌៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

## វគ្គទី៥

## ប្រធានបទ៖ ការអត់ឃ្លាន និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

*ដោយ ៖ វ៉េនឌល ឌឹហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ ៖ ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*

*ខែកក្កដា ឆ្នាំ២០១៣*

*ជម្រាបសួរប្រិយមិត្តអ្នកស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី! នេះគឺជាការផ្សាយវគ្គទី៥ ក្នុងចំណោមការផ្សាយទាំង១០វគ្គនៃកម្មវិធីវិទ្យុរបស់យើងខ្ញុំ ដែលពិនិត្យទៅលើទិដ្ឋភាពប្រវត្តិសាស្រ្ត និងច្បាប់ផ្សេងៗទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ គោលបំណងសំខាន់របស់កម្មវិធីវិទ្យុនេះ គឺដើម្បីផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងច្បាស់អំពីសាច់រឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ព័ន្ធនឹងការអត់ឃ្លាន និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិ-ធម៌ ។ កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យតាមរយៈវិទ្យុដូចខាងក្រោម ។ វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ ។ រៀងរាល់ដើមខែ យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយជូនប្រិយមិត្តអ្នកស្តាប់ ។ ចំពោះប្រិយមិត្តអ្នកស្តាប់ដែលរស់នៅរាជធានីភ្នំពេញ និងខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំ តាមរយៈវិទ្យុជាតិកម្ពុជា FM105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង ១រសៀល និង ម៉ោង៧និង៣០នាទីល្ងាច ។ នៅខេត្តកំពត តាមរយៈ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និង ម៉ោង៧ល្ងាច ។ នៅខេត្តព្រះវិហារ តាមរយៈ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។*

នៅខេត្តបាត់ដំបង តាមរយៈវិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង ៨ព្រឹក និងម៉ោង៤រសៀល ។

ការផ្សាយក្នុងវគ្គទី៥នេះ យើងខ្ញុំផ្តោតសំខាន់ទៅលើ ការអត់ឃ្លាន និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ យើងខ្ញុំនឹងបកស្រាយអត្ថន័យនៃពាក្យ «ឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ» ព្រមទាំងលើកយកឧក្រិដ្ឋកម្មផ្សេងៗមកពិភាក្សា ដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងឧក្រិដ្ឋកម្មទាំងនោះទៅនឹងភាពអត់ឃ្លាន ដែលបានកើតនៅក្នុងបរិបទទូទៅ ក៏ដូចជានៅក្នុងប្រទេសកម្ពុជា ។

មុននឹងយើងចាប់ផ្តើមបទអត្ថាធិប្បាយវគ្គទី៥នេះ យើងខ្ញុំសូមជម្រាបជូនប្រិយមិត្តអ្នកស្តាប់ អំពីការវិវឌ្ឍរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ រយៈពេលថ្មីៗកន្លងទៅនេះ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកំពុងស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីបានពោលរៀបរាប់ពីរឿងរ៉ាវផ្ទាល់របស់ខ្លួន ដែលផ្តោតទៅលើភាពលំបាកវេទនា អំពើហិង្សា និងភាពអត់ឃ្លានដែលខ្លួនបានជួបប្រទះ ។ ទន្ទឹមនឹងការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម នួន ជា បានសម្តែងនូវការសោកស្តាយ និងបានឆ្លើយទទួលខុសត្រូវដោយផ្នែកចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ នួន ជា បានលើកឡើងថា៖ «ក្នុងនាមជាមេដឹកនាំខ្មែរក្រហមមួយរូប ខ្ញុំមិនមែនគេចពីការទទួលខុសត្រូវទេ ។ ខ្ញុំសូមចូលរួមចំណែកទទួលខុសត្រូវ ។ ប៉ុន្តែ ខ្ញុំគ្មានតួនាទីអីខាងនីតិប្រតិបត្តិទេ ។» នួន ជា ក៏បានបញ្ជាក់បន្ថែមទៀតថា៖ «ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ការខូចខាត ការគ្រោះថ្នាក់របស់ជាតិខ្ញុំ ក្នុងឋានៈខ្ញុំជាម្នាក់ទទួលនាទីដឹកនាំ ខ្ញុំត្រូវតែទទួលការខុសត្រូវ ។ ខ្ញុំសូមទទួលដោយស្មោះអស់ពីដួងចិត្ត ។... ខ្ញុំសោកស្តាយណាស់ចំពោះព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើង ដោយចេតនា ឬអចេតនា ។ ហើយទោះបីជាខ្ញុំដឹង ឬមិនដឹងក៏ដោយ ។» ទោះបីជា សេចក្តីថ្លែងការណ៍របស់ នួន ជា មិនបានបង្ហាញពីការទទួលខុសត្រូវតាមផ្លូវច្បាប់ ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មកលើខ្លួនក៏ដោយ ក៏សេចក្តីថ្លែងការណ៍នេះ បានបង្ហាញថា នួន ជា បានទទួលខុសត្រូវចំពោះការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនខ្លួនក្នុងរបបខ្មែរក្រហម ។

## *សេចក្តីផ្តើមៈ តើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាអ្វី?*

ពាក្យ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ត្រូវបានប្រើប្រាស់ដំបូងបង្អស់ ដើម្បីសំដៅទៅលើឧក្រិដ្ឋកម្មអន្តរជាតិមួយ ដែលបានកើតឡើងនៅក្នុងឆ្នាំ១៩១៥ ។ នៅពេលនោះ រដ្ឋាភិបាលបារាំង អង់គ្លេស និងសូវៀត បានចេញសេចក្តីប្រកាសរួមគ្នាមួយ ដើម្បីចោទប្រកាន់ជនជាតិអាមានា (Armenia) ពីបទ សម្លាប់រង្គាលនៅក្នុងចក្រភពទួរគីអូតូម៉ែន (Turkish Ottoman Empire) ។ ការសម្លាប់នេះត្រូវបានទទួលស្គាល់ថាជា "ឧក្រិដ្ឋកម្មថ្មី ដែលប្រឆាំងនឹងមនុស្សជាតិ និងអារ្យធម៌ជនជាតិទួរគី" ដែលក្នុងនោះរួមមាន "សមាជិក និងភ្នាក់ងារទាំងអស់នៃចក្រភពអូតូម៉ែន (Ottoman Empire) ដែលជាប់ពាក់ព័ន្ធទៅនឹងវិនាសកម្មនេះ" ។ បើទោះបីជាពុំមានការកាត់ក្តីណាមួយត្រូវបានធ្វើឡើងក៏ដោយ ប៉ុន្តែ សន្និសញ្ញានេះបានក្លាយជាចំណុចចាប់ផ្តើមនៃការកើតមាន ច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ បន្ទាប់ពីសង្គ្រាមលោកលើកទី២ ។ ជាក់ស្តែង លោក អាប់ឌុល អ៊ិចម៉ាន់ (Adolf Eichmann) ត្រូវបានតុលាការថ្នាក់ស្រុករបស់ប្រទេសអ៊ីស្រាអែលផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ បន្ទាប់មក ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានតុលាការជាច្រើន ដូចជា នៅប្រទេសយូហ្គោស្លាវី (Yugoslavia) រ៉្វាន់ដា (Rwanda) សេរ៉ា-លេអូន (Sierra Leone) និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ក៏ដូចជា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម យកមកប្រើប្រាស់ ដើម្បីចោទប្រកាន់ជនជាប់ចោទ ។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាសំណុំនៃឧក្រិដ្ឋកម្មដែលត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ដែលឧក្រិដ្ឋកម្មនេះឆ្លុះបញ្ចាំងនូវ "ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល" ។ ការវាយប្រហារជាទូទៅ សំដៅទៅលើការវាយប្រហារដែលកើតឡើងពេញផ្ទៃប្រទេស ឬកើតឡើងក្នុងរយៈពេលយូរ ។ រីឯ ការវាយប្រហារជាប្រព័ន្ធ គឺជាការវាយប្រហារដោយចំពោះដែលមានគម្រោង និងការរៀបចំទុកជាមុន ។ ចំណុចទាំងពីរខាងលើនេះ គឺជាសមាសធាតុយោងសំខាន់ដើម្បីអាចកាត់សេចក្តីបានថា ជនណាម្នាក់ជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ យើងអាចកាត់សេចក្តីថា ជនណាម្នាក់ជាប់ចោទពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិបាន លុះត្រាតែការវាយប្រហារទាំងពីរខាងលើនេះត្រូវបានបង្ហាញឲ្យឃើញ ។ ជាក់ស្តែង នៅក្នុងបរិបទនៃរបបខ្មែរក្រហម យើងសង្កេតឃើញមានសកម្មភាពជាច្រើន ដែលស្ថិតក្នុងការវាយប្រហារទាំងពីរដែលបានរៀបរាប់ខាងដើម ដែលខ្មែរក្រហមបានប្រព្រឹត្តិលើប្រជាជនកម្ពុជា ដូចជា ការកាប់សម្លាប់ ការរំលោភបំពាន ការបង្ខំឲ្យធ្វើការហួសកម្លាំង និងគោលនយោបាយផ្សេងៗទៀត ដែលសុទ្ធសឹងតែបានប្រព្រឹត្តិឡើង

ជាទូទៅ និងជាប្រព័ន្ធ ។ មិនតែប៉ុណ្ណោះ សកម្មភាពទាំងនេះ បានកើតឡើងក្នុងទ្រង់ទ្រាយធំស្ទើរគ្រប់តំបន់នៃប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម និងមានរយៈពេលរហូតដល់ជាង៣ឆ្នាំ ។ ជាងនេះទៅទៀត សកម្មភាពទាំងនោះ ត្រូវបានបញ្ជាដោយផ្ទាល់ពីបក្សកុម្មុយនិស្តកម្ពុជាដែលមានទីតាំងកណ្តាលនៅទីក្រុងភ្នំពេញ ។ ដូច្នេះ ក្នុងចំណោមឧក្រិដ្ឋអន្តរជាតិទាំងបី រួមមានអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាបទចោទប្រកាន់មួយដែលអាចយកមកធ្វើការចោទប្រកាន់បាន ចំពោះការឈឺចាប់ និងស្លាប់បាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាដែលបង្កឡើងដោយខ្មែរក្រហម ។

ទន្ទឹមនឹងនេះដែរ គោលនយោបាយដទៃទៀតរបស់ខ្មែរក្រហម ដែលទាក់ទងទៅនឹងលក្ខខណ្ឌរស់នៅដូចជា កង្វះខាតចំណីអាហារ ការធ្វើការហួសកម្លាំង និងការគំរាមធ្វើទារុណកម្មចំពោះជនណាដែលលួចរកអាហារបន្ថែម ក៏អាចចាត់ទុកថាជាផ្នែកមួយដែលនាំឲ្យមានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធទៅលើប្រជាជនកម្ពុជាដែរ ។ ជាបន្តទៅទៀត យើងនឹងធ្វើការបកស្រាយអំពីទំនាក់ទំនងរវាងការអត់ឃ្លាន និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលពាក់ព័ន្ធនឹងការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗ ។

## ការសម្លាប់រង្គាល

ការសម្លាប់រង្គាល គឺជាឧក្រិដ្ឋកម្មមួយដែលកើតចេញពីការសម្លាប់ក្នុងទ្រង់ទ្រាយធំដោយផ្ទាល់ ឬដោយប្រយោល រួមមាន "ការបង្ខំជនណាម្នាក់ឲ្យរស់នៅក្នុងស្ថានភាពលំបាកដែលអាចបណ្តាលឲ្យជននោះបាត់បង់ជីវិត" ។ យោងតាមមាត្រា៧នៃច្បាប់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានបញ្ជាក់ថា ការសម្លាប់រង្គាលអាចធ្វើឡើងតាមរយៈ "ការបង្អត់អាហារ និងថ្នាំសង្កូវ" ។ នៅក្នុងរបបខ្មែរក្រហម ភាពអត់ឃ្លានដែលបានបង្កឲ្យមនុស្សរាប់សែននាក់ស្លាប់បាត់បង់ជីវិត បានឆ្លើយតបទៅនឹងនិយមន័យនៃ "ការសម្លាប់រង្គាល" ។ មិនតែប៉ុណ្ណោះ ការស្លាប់របស់ប្រជាជនកម្ពុជាដ៏ច្រើនសន្ធឹកសន្ធាប់នេះ បានកើតឡើងដោយសារគោលនយោបាយរបស់ខ្មែរក្រហម ដែលមជ្ឈិមបក្សបានដាក់ចេញ ។ គោលនយោបាយទាំងនោះរួមមាន ការបង្ខំឲ្យធ្វើការហួសកម្រិត ការបង្ខំឲ្យរស់នៅនិងហូបចុកជាសមូហភាព ការហាមមិនឲ្យធ្វើការបង្កបង្កើនផលជាលក្ខណៈឯកជន និងការគំរាមប្រើអំពើហិង្សា បានធ្វើឲ្យប្រជាជនកម្ពុជាទទួលរងនូវបាក់កម្លាំង និងទទួលទានអាហារមិនគ្រប់គ្រាន់ ។

ជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថា ជាប់ចោទពីបទសម្លាប់រង្គាល ក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លុះត្រាតែជននោះ «មានគោលបំណងបង្ខំប្រជាជនឲ្យរស់នៅក្នុងស្ថានភាពមួយដែលអាចបណ្តាលឲ្យពួកគាត់ស្លាប់បាត់បង់ជីវិត ដោយការចាប់បង្ខំនេះធ្វើឡើងជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ ។»

ភស្តុតាងជាច្រើនដែលមិនអាចប្រកែកបានបង្ហាញថាការអត់ឃ្លានពិតជាបានកើតឡើង និងមានសភាពកាន់តែធ្ងន់ធ្ងរឡើងនៅក្នុងប្រទេសកម្ពុជានារបបខ្មែរក្រហម ហើយមេដឹកនាំខ្មែរក្រហមក៏បានដឹងថាប្រជាជនរបស់ខ្លួនរាប់សែននាក់កំពុងតែជួបប្រទះការខ្វះខាតស្បៀងអាហារ ។ ភស្តុតាងទាំងនោះមានដូចជា បទសម្ភាសន៍ជាមួយអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម និងសក្ខីកម្មនានាដែលបានរៀបរាប់នៅមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បើទោះបីជា មេដឹកនាំខ្មែរក្រហមទាំងនោះដឹងថាប្រជាជនរបស់ខ្លួនកំពុងរងគ្រោះដោយសារការអត់ឃ្លាន ក៏មេដឹកនាំទាំងនោះនៅតែបន្តដាក់ចេញគោលនយោបាយផ្សេងៗទៀត ដែលបានបន្តឲ្យការអត់ឃ្លានមានសភាពធ្ងន់ធ្ងរឡើងៗ ។ ជាលទ្ធផល ប្រសិនបើសមាជិកមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ពិតជាបានប្រព្រឹត្តិនូវទង្វើដូចដែលបានរៀបរាប់ខាងលើនោះមែន នោះមេដឹកនាំខ្មែរក្រហមអាចនឹងជាប់ទោសពីបទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារតែមេដឹកនាំខ្មែរក្រហមទាំងនោះ បានរួមចំណែកក្នុងការសម្លាប់ប្រជាជនកម្ពុជា តាមរយៈការបង្ខំឲ្យប្រជាជនទាំងនោះរស់នៅក្នុងភាពអត់ឃ្លាន ។ ហេតុដូច្នេះហើយ នៅក្នុងករណីខ្មែរក្រហម ក៏ដូចជាករណីផ្សេងទៀត ការសម្លាប់រង្គាល គឺជាឧក្រិដ្ឋកម្មអន្តរជាតិមួយ ដែលបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំតាមរយៈការបង្កឲ្យមានភាពអត់ឃ្លាន ។

## ការធ្វើទុក្ខបុកម្នេញ

បើទោះបីជាភាពអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម បានប៉ះពាល់ដល់ប្រជាជនទូទៅ ក៏ប៉ុន្តែ ការអត់ឃ្លានរបស់ជនដែលត្រូវបានចាត់ទុកជាសត្រូវនយោបាយរបស់បដិវត្តន៍រិតតែមានសភាពធ្ងន់ធ្ងរ ។ ជនទាំងនេះរួមមាន អ្នកដែលរស់នៅក្នុងតំបន់គ្រប់គ្រងរបស់រដ្ឋាភិបាល លន់ នល់ ដូចជា បញ្ញាវន្ត អ្នករស់នៅទីក្រុង និងអតីតមន្ត្រីរាជការក្នុងរបប លន់ នល់ ត្រូវបានចាត់ទុកថាជា «ប្រជាជនថ្មី ឬ ប្រជាជន១៧ មេសា» ត្រូវបានបង្ខំឲ្យរស់នៅក្នុងលក្ខខណ្ឌលំបាកបំផុត ។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការធ្វើទុក្ខបុកម្នេញ គឺជាការបំបិទសិទ្ធិមូលដ្ឋានទាំងឡាយណា ដែលស្ថិតក្រោមការពារនៃច្បាប់អន្តរជាតិ ។ ការធ្វើទុក្ខបុកម្នេញនោះ ធ្វើឡើងដោយចេតនា និង

ប្រព្រឹត្តិឡើងក្នុងគោលបំណងរើសអើង ជាតិសាសន៍ សាសនា ឬនយោបាយណាមួយ ។ យោងតាមនិយមន័យខាងលើ ទង្វើដែលបានបង្កឡើងដោយមជ្ឈិមបក្សរបស់ខ្មែរក្រហម គួរត្រូវបានជាប់ទោសពីបទធ្វើទុក្ខបុកម្នេញ ព្រោះមេដឹកនាំខ្មែរក្រហមបានបង្ខំឲ្យប្រជាជនថ្មីរស់នៅក្នុងការអត់ឃ្លាន ។

មជ្ឈិមបក្សខ្មែរក្រហម បានដាក់បញ្ជាឲ្យជម្លៀសប្រជាជន«ថ្មី» ទៅកន្លែងណាត្រូវការកម្លាំងពលកម្មច្រើន ។ នៅតាមផ្លូវធ្វើដំណើរ ប្រជាជនថ្មីទាំងនោះមិនបានទទួលអាហារគ្រប់គ្រាន់នោះទេ ហើយកន្លែងដែលប្រជាជនថ្មីត្រូវបានជម្លៀសទៅ ពុំមានអាហារបរិភោគគ្រប់គ្រាន់ ឬផ្ទះស្នាក់នៅត្រឹមត្រូវនោះទេ ។ ជាក់ស្តែង ការជម្លៀសប្រជាជននៅភូមិភាគពាយ័ព្យក្នុងទ្រង់ទ្រាយធំ ។ ទន្ទឹមនឹងនេះប្រជាជនថ្មី ត្រូវរស់នៅដោយកង្វះអនាម័យ និងចំនីអាហារមិនស្អាត ដែលជាមូលហេតុនៃការអត់ឃ្លាន និងជម្ងឺផ្សេងៗ ។ ជាមួយគ្នានេះដែរ មជ្ឈិមបក្សក៏បានចាត់ទុកប្រជាជនថ្មី ជាសត្រូវរបស់បដិវត្តន៍ ហើយបានចាត់ទុកពួកគេថាជា "ជនបញ្ញើក្អែក" ទុកក៏មិនចំណេញ ដកចេញក៏មិនខាត ។ ប្រជាជនថ្មីនេះទៀតសោត ត្រូវបានខ្មែរក្រហមទម្លាក់កំហុស ក្នុងករណីដែលខ្មែរក្រហមតាមមូលដ្ឋាន មិនអាចសម្រេចបាននូវទិន្នផលកសិកម្មដែលបានដាក់ឲ្យដោយមជ្ឈិមបក្ស ។ ជាក់ស្តែង នៅពេលដែលទិន្នផលស្រូវមិនអាចសម្រេចបាន ប្រជាជនថ្មីត្រូវបានចាប់ខ្លួន និងបង្ខំឲ្យសារភាពថា បានបំផ្លិចបំផ្លាញផលដំណាំមុនពេលដែលប្រជាជនថ្មីនោះត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ។ ដូច្នេះ ការរើសអើងចំពោះប្រជាជនថ្មី រួមផ្សំនឹងលក្ខខណ្ឌរស់នៅលំបាកវេទនា អាចបំពេញនូវធាតុផ្សំ នៃការធ្វើទុក្ខបុកម្នេញ ដោយការបង្ខាំងសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនថ្មីទាំងនោះ ដែលពាក់ព័ន្ធនឹង សុខភាព សេចក្តីថ្លៃថ្នូរ និងរូបរាងកាយ ។

## អំពើអមនុស្សធម៌ផ្សេងៗ

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីអំពើអមនុស្សធម៌ដទៃទៀត គឺជាទង្វើទាំងឡាយដែលបង្ហាញពីការធ្វើទុក្ខទោសទៅលើជនស៊ីវិល ដែលមិនមែនជាការសម្លាប់រង្គាល ឬការធ្វើទុក្ខបុកម្នេញដូចបានរៀបរាប់ខាងលើ ។ ប៉ុន្តែ អំពើអមនុស្សធម៌នោះ ក៏មានស្ថានទម្ងន់ទោសធ្ងន់ធ្ងរដែរ ។ គណៈកម្មាការច្បាប់អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស យូហ្គោស្លាវី និងប្រទេសរ្វ៉ាន់ដា បានធ្វើសេចក្តីសន្និដ្ឋានថា ស្ថានទម្ងន់ទោសធ្ងន់ធ្ងរ សំដៅទៅលើទង្វើទាំងឡាយណា ដែលបង្ករបួសដល់ជនរងគ្រោះ ជាពិសេសទៅលើរូបរាងកាយ សតិអារម្មណ៍ សុខភាព ក៏ដូចជា ភាពថ្លៃថ្នូររបស់បុគ្គលនោះ ។

ការរងគ្រោះដោយសារការអត់ឃ្លាន រួមមាន ការប៉ះពាល់ផ្នែកផ្លូវកាយ និងសតិអារម្មណ៍ ព្រមទាំងសុខភាព និងថ្លៃថ្នូររបស់របស់មនុស្ស ។ ផលប៉ះពាល់ដែលបានរៀបរាប់នេះ បានកើតមានចំពោះប្រជាជនកម្ពុជា ក្នុងអំឡុងពេលដែលមានការអត់ឃ្លានកើតឡើងនៅក្នុងរបបខ្មែរក្រហមអស់រយៈពេលជាងបីឆ្នាំ ។ នៅក្នុងអំឡុងពេលនៃភាពអត់ឃ្លាននេះ កម្លាំងកាយរបស់ប្រជាជនកម្ពុជាបានចុះទ្រុឌទ្រោមជារៀងរាល់ថ្ងៃ ដោយសារតែកង្វះខាតអាហារបរិភោគ ការធ្វើការងារហួសកម្លាំង និងការប្រឈមមុខនឹងអំពើហិង្សាជាប្រចាំ ។ ជាការពិតណាស់ នៅពេលដែលយើងសួរអំពីបទពិសោធន៍ជីវិតរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ជនរងគ្រោះទាំងនោះតែងតែសង្កត់ធ្ងន់ទៅលើការអត់ឃ្លាន ដែលជាកត្តាចំបងដែលចង់ឲ្យតុលាការលើកឡើងនៅក្នុងការកាត់សេចក្តី ។ លើសពីនេះទៅទៀត ដូចដែលបានពិភាក្សាពីខាងលើ ប្រសិនបើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចបញ្ជាក់បានថា បក្សមជ្ឈិមបានដឹងថា ប្រជាជនកម្ពុជាកំពុងរស់នៅក្នុងស្ថានភាពអមនុស្សធម៌ ដូចជា ការអត់ឃ្លានធ្ងន់ធ្ងរ ប៉ុន្តែ មេដឹកនាំទាំងនោះនៅតែបន្តអនុវត្តគោលនយោបាយរបស់ខ្លួន នោះមេដឹកនាំទាំងនោះត្រូវតែទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីអំពើអមនុស្សធម៌ផ្សេងៗ ដោយសារតែ មេដឹកនាំទាំងនោះបានបង្កប្រជាជនកម្ពុជារស់នៅក្នុងស្ថានភាពលំបាកវេទនា ជាពិសេសបង្កឲ្យមានភាពអត់ឃ្លានកើតឡើង ។

អំពើអមនុស្សធម៌ គឺជាបទឧក្រិដ្ឋមួយដ៏សំខាន់សម្រាប់បរិយាយអំពីរឿងរ៉ាវទាំងមូល នៃការរងគ្រោះដោយសារភាពអត់ឃ្លាន ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ។ នេះក៏ដោយសារតែ ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ ពាក់ព័ន្ធទាំងស្រុងទៅនឹងការសម្លាប់ជាទ្រង់ទ្រាយធំ និងការធ្វើទុក្ខបុកម្នេញទៅលើក្រុមមនុស្សណាមួយដោយចំពោះ ។ ផ្ទុយទៅវិញ អំពើអមនុស្សធម៌ រួមបញ្ចូលនូវទុក្ខលំបាកវេទនាជាទូទៅ បើទោះបីជាទុក្ខលំបាកវេទនានោះមិនបានបង្កឲ្យមានការស្លាប់បាត់បង់ជីវិតក៏ដោយ ហើយអំពើអមនុស្សធម៌នោះបានកើតឡើងដល់ប្រជាជនស៊ីវិលទាំងអស់ ដោយមិនរើសអើងចំពោះជនជាតិណាមួយឡើយ ។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីអំពើអមនុស្សធម៌ អាចត្រូវបានយកមកចោទប្រកាន់មេដឹកនាំខ្មែរក្រហម ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តិតាមរយៈគោលនយោបាយរបស់ខ្លួន ទៅលើរូបរាងកាយ និងសតិអារម្មណ៍របស់ជនគ្រោះ ។ រហូតមកដល់សព្វថ្ងៃនេះ ការប៉ះទង្គិចផ្លូវចិត្ត និងបញ្ហាសុខភាព នៅតែបន្តជាបញ្ហាប្រឈមដល់អ្នកដែលរស់រានមានជីវិតពីភាពអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមនៅឡើយ ។

ជាសរុប យើងអាចសន្និដ្ឋានបានថា គោលនយោបាយរបស់មជ្ឈិមបក្សខ្មែរក្រហម បានបង្កឲ្យមានភាពអត់ឃ្លាននៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ហើយបានបង្កជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារតែ ទង្វើរបស់ខ្មែរក្រហមបានបង្កឲ្យមានផលប៉ះពាល់«ជាទូទៅ» និង«ជាប្រព័ន្ធ។» ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃផ្សេងទៀត អាចយកមកប្រើប្រាស់ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលពាក់ព័ន្ធនឹងសោកនាដកម្មទាំងឡាយដែលបានកើតឡើងដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម។

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម អាចនឹងមិនលើកយកបញ្ហាដែលពាក់ព័ន្ធនឹងលក្ខណរស់នៅ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមមកពិភាក្សាជាពិស្តារ ហើយកម្មវិធីវិទ្យុរបស់យើងខ្ញុំ ក៏មិនមានចេតនាបង្ខំឲ្យតុលាការលើកពីបញ្ហានេះមកកាត់សេចក្តីដោយខាងតែបាននោះទេ។ មិនតែប៉ុណ្ណោះ ប្រសិនបើមិនមានសាលក្រមចុងក្រោយរបស់តុលាការថាឧក្រិដ្ឋកម្មដែលបានលើកឡើងខាងលើត្រូវបានចោទប្រកាន់ចំពោះការអត់ឃ្លានដែលបានកើតឡើងនោះទេ ដូច្នេះវាស្ថិតនៅលើទស្សនៈរបស់បុគ្គលម្នាក់ៗ អំពីបទឧក្រិដ្ឋដែលខ្មែរក្រហមបានប្រព្រឹត្តិ ជាពិសេស ការបង្កឲ្យមានភាពអត់ឃ្លានចំពោះប្រជាជនកម្ពុជានៅក្នុងសម័យខ្មែរក្រហម ថាតើវាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬទេ។

*(ជាបន្តទៅនេះ យើងខ្ញុំសូមលើកយកអត្ថបទមួយក្រោមចំណងជើងថា "ភូមិមេម៉ាយ" ចេញផ្សាយដោយទស្សនាវដ្តី«ស្វែងរកការពិត»របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ៥៦ ខែសីហា ឆ្នាំ២០០៤ សរសេរដោយ ឡុង ដានី។)*

# ភូមិមេម៉ាយ

ប្រជាជនភាគច្រើននៅក្នុងភូមិព្រះឱង្ការគឺជាស្ត្រីមេម៉ាយ ព្រោះប្តីៗរបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលអស់ហើយ ។ បច្ចុប្បន្ននេះ ស្ត្រីមេម៉ាយទាំងនោះកំពុងតែទន្ទឹងរង់ចាំថ្ងៃដែលសាលាក្តីដើម្បីជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម លេចជារូបរាងឡើង ។ នៅពេលដែលឱកាសនោះមកដល់ ស្ត្រីមេម៉ាយនៅភូមិព្រះឱង្ការចង់សួរទៅអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងនោះថា តើហេតុអ្វីបានជាអង្គការយកប្តីនិងកូនប្រុសរបស់គាត់ទៅសម្លាប់ ។

ភូមិព្រះឱង្ការស្ថិតនៅក្នុងឃុំម្រោម ស្រុកអង្គរជ័យ ចម្ងាយប្រមាណ៧គីឡូម៉ែត្រខាងជើងផ្សារតានី ។ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧២ ភូមិព្រះឱង្ការស្ថិតក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរ ។ នៅពេលខ្មែរក្រហមវាយដណ្តើមកាន់កាប់ស្រុកអង្គរជ័យបានទាំងស្រុងនៅចុងឆ្នាំ១៩៧២ រដ្ឋអំណាចខ្មែរក្រហមបានចាត់ចែងរៀបចំប្រជាជនដែលរស់នៅតាមភូមិតាមឃុំឲ្យចូលរួមធ្វើជាសហករណ៍ (គឺរស់នៅតាមផ្ទះរៀងៗខ្លួន ប៉ុន្តែធ្វើការរួមនិងហូបរួម) ។ នៅពេលនោះ អង្គការក៏ចាប់ផ្តើមបែងចែកប្រជាជនទៅតាមវណ្ណៈផ្សេងៗពីគ្នា ដូចជា អ្នកមាន អ្នកក្រ អ្នករស់នៅតំបន់ខ្មាំង និងអ្នករស់នៅតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ។

អ្នកដែលរស់ក្នុងភូមិព្រះឱង្ការត្រូវចាត់ទុកថាជាប្រជាជនរស់នៅតំបន់ខ្មាំង ។ នៅមុនរបបខ្មែរក្រហម អ្នកភូមិព្រះឱង្ការភាគច្រើនមានជីវភាពធូរធារ និងសម្បូរទៅដោយផ្ទះធំៗសង់អំពីឈើប្រក់ក្បឿង ។ ដោយសារភូមិព្រះឱង្ការមានលក្ខណៈអំណោយផលពីធម្មជាតិ ប្រជាជនអាចធ្វើស្រែចម្ការនិងដាំដំណាំហូបផ្លែផ្សេងៗដូចជា ម្រេច ដូង ស្វា ក្រូច ស្វាយ មាក់ប្រេង មាក់ប្រាង ខ្នុរ ទៀប ម្នាស់ ចេក ជាដើម ។ ក៏ប៉ុន្តែចាប់តាំងពីខ្មែរក្រហមចូលមកកាន់កាប់ ភូមិព្រះឱង្ការលែងមានភាពរស់រវើកដូចមុនទៀតហើយ ។ អង្គការបានចេញបញ្ជាឲ្យប្រជាជនបោះបង់ចោលទាំងអស់នូវរបរធ្វើចម្ការនិងដាំដំណាំផ្សេងៗ ហើយឲ្យប្រជាជនធ្វើស្រែតែមួយមុខប៉ុណ្ណោះ ។ ចំណែកផ្ទះសម្បែងរបស់ប្រជាជនដែលសង់អំពីឈើប្រក់ក្បឿងនិងមានទំហំធំៗនោះ ត្រូវអង្គការបញ្ជាឲ្យរុះរើយកឈើទៅធ្វើស្ពាននិងធ្វើអុសដុត ។

បើតាមសម្តីរបស់អ្នកភូមិព្រះឱង្ការបានឲ្យដឹងថា គណៈស្រុកអង្គរជ័យឈ្មោះ យន់ និង បូ ។ គណៈឃុំម្រោមឈ្មោះ ហុន និង ឆុន ជាមនុស្សមកពីចម្ងាយ គឺមកពីស្រុក១០៥ (ស្រុកត្រាំកក់ ខេត្តតាកែវ) ។ យន់, បូរ, ហុន និង ឆុន បានកោះហៅប្រជាជននៅភូមិព្រះឱង្ការទៅប្រជុំជាញឹកញាប់អំពីផែនការលើកទំនប់ជីកប្រឡាយនិងធ្វើស្រែដើម្បីកសាងប្រទេសជាតិឲ្យបានរីកចម្រើនឆាប់រហ័ស ។ នៅពេលប្រជុំម្តងៗ រដ្ឋអំណាចខ្មែរក្រហមនិយាយជាញយៗថា បើអ្នកណាដើរមិនទាន់កង់ប្រវត្តិសាស្ត្រទេ កង់ប្រវត្តិសាស្ត្រនឹងវិលកិនហើយ ប៉ះដៃដាច់ដៃ ប៉ះជើងដាច់ជើង និយាយរួមគឺប៉ះចំកន្លែងណាដាច់កន្លែងហ្នឹង ។ អ្នកភូមិព្រះឱង្ការបានឲ្យដឹងទៀតថា ពេលដែលរដ្ឋអំណាចខ្មែរក្រហមកោះហៅប្រជាជនឲ្យចូលរួមប្រជុំម្តងៗ ពួកគេតែងតែកត់ឈ្មោះនិងកត់សម្គាល់ភិនភាគរបស់ប្រជាជនម្នាក់ៗជានិច្ច ។

នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានចាប់ផ្តើមចាប់ប្រជាជនដែលរស់នៅតាមភូមិស្រុកយកទៅសម្លាប់ដោយចោទពីបទខ្មាំងផ្សេងៗដូចជាសេ.អ៊ី.អារបស់អាមេរិកាំង ជាមេដប់ខ្នង ឬមេហាសិបខ្នងជាដើម ។ ក្នុងរយៈពេលប្រមាណតែ២ខែប៉ុណ្ណោះ បុរសៗដែលរស់នៅក្នុងភូមិព្រះឱង្ការត្រូវអង្គការចាប់យកទៅសម្លាប់ចោលស្ទើរតែទាំងអស់ ។ បុរសៗដែលបានរួចផុតពីការសម្លាប់របស់ខ្មែរក្រហមមានចំនួនតែ១៦នាក់ប៉ុណ្ណោះ គឺឈ្មោះ ឡូយ, អ៊ី, ត្រាន់, ឈួន, នួរ, គ្រិច, គ្រៀង, កប, អាន, ញ៉ៃ, ងិន, អាយ, ដាន, ដូ, ដុន និង ចាំង» ។

យាយ ប៉ាន់ គ្រីស អាយុ៨០ឆ្នាំ, អ៊ំស្រី ឈូក សើន អាយុ៦៦ឆ្នាំ និងមីង ហង់ គ្រិន អាយុ៥២ឆ្នាំ ជាស្ត្រីមេម៉ាយដោយសារខ្មែរក្រហម ។ ប្តីរបស់ យាយគ្រីស ឈ្មោះ ហង់ នាក់ និងកូនប្រុសឈ្មោះ ហង់ ដាត ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅ

ឆ្នាំ១៩៧៤ ។ យាយ គ្រីស បានរៀបរាប់ថា «តាំងពីដើមរៀង មក ក្នុងគ្រួសារខ្ញុំមិនដែលមានអ្នកណាធ្វើនយោបាយអីទេ គឺគិតតែខំធ្វើស្រែចម្ការនិងរកស៊ីចិញ្ចឹមគ្រួសារប៉ុណ្ណោះ ។ ស្រាប់តែនៅឆ្នាំ១៩៧៤ ខ្មែរក្រហមចាប់ប្តីនិងកូនប្រុសខ្ញុំយកទៅដោយចោទថាជាខ្មែរសេ.អ៊ី.អារបស់អាមេរិកាំង ។» ពេលនោះ យាយ គ្រីស បានសួរគណៈឃុំឈ្មោះ ហុន ថា «យកប្តីនិងកូនប្រុសរបស់ខ្ញុំទៅណា?» ។ ហុន ឆ្លើយថា «អង្គការមិនយកទៅណាទេ គឺឲ្យគាត់ទៅរៀនសូត្រកសាងខ្លួន» ។

ប្តីរបស់ ឈួក សើន ឈ្មោះ ឈុន តាន់ ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅវត្តភ្នំឆ្នារក្នុងឃុំម្រោម ។ គណៈឃុំបានប្រាប់ សើន និងកូនៗថាយក តាន់ ទៅរៀនសូត្រ ។

ហង់ គ្រិន បាននិយាយថា «តាំងពីឆ្នាំ១៩៧០ ពេលដែលខ្ញុំរៀបការជាមួយប្តីខ្ញុំឈ្មោះ អ៊ន់ នូវ រហូតដល់មានកូនបីនាក់ ខ្ញុំមិនដែលដឹងនិងមិនដែលបានឃើញប្តីរបស់ខ្ញុំទាក់ទងជាមួយអ្នកណាអំពីរឿងនយោបាយឡើយ ។ គាត់គិតតែពីខំប្រឹងប្រែងធ្វើស្រែចម្ការនិងដាំដំណាំផ្សេងៗសម្រាប់ផ្គត់ផ្គង់គ្រួសារតែប៉ុណ្ណោះ ។» គ្រិន បានបន្តទៀតថា នៅអំឡុងឆ្នាំ១៩៧៤ គណៈស្រុកអង្គរជ័យឈ្មោះ យន់ និងគណៈឃុំម្រោមឈ្មោះ ហុន និង ឆុន ចុះមកប្រជុំជាមួយប្រជាជនជាញឹកញាប់ ក្នុងមួយសប្តាហ៍យ៉ាងហោចណាស់២ដងដែរ ។ នៅក្នុងពេលប្រជុំម្តងៗ ឈ្លបឃុំតែងតែមកចាប់ប្រជាជន ជួនកាល៥-៦នាក់ ជួនកាល ៩-១០នាក់យកទៅសម្លាប់ ។

យិន ស៊ី អាយុ៦៥ឆ្នាំ បាននិយាយថា «គ្រួសារខ្ញុំរស់នៅប្រកបមុខរបរតែធ្វើស្រែចម្ការ មិនដែលមានការពាក់ព័ន្ធជាមួយនយោបាយឡើយ ។ ស្រាប់តែនៅឆ្នាំ១៩៧៤ គណៈឃុំឈ្មោះ ហុន បានហៅប្តីរបស់ខ្ញុំឈ្មោះ ហ៊ាង ហ៊ី ពីកន្លែងប្រជុំនៅរោងបាយរបស់ភូមិយកទៅបាត់រហូតមកដល់សព្វថ្ងៃ ។»

យាយ នឹម ជ្រឹម អាយុ៧៣ឆ្នាំ ក៏បានប្រាប់យើងដែរថា «ប្តីខ្ញុំជាចាស់ទុំនៅក្នុងភូមិព្រះឱង្ការ គាត់ជាកសិករសុទ្ធសាធ ចុះហេតុអ្វីបានជាអង្គការហៅគាត់ទៅយកទៅសម្លាប់?» ។

មានប្រជាជនមួយចំនួនទៀតត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងគ្រួសារតែម្តង ក្នុងនោះមានគ្រួសារ តាម៉ុកធន់-យាយយ៉ែម, គ្រួសារ តាប៊ិន-យាយយ៉ប់ និងគ្រួសារ តាងឹមតាន-យាយផាត ។ តាម៉ុកធន់ និង តាប៊ិន ជាមនុស្សចាស់មានជំងឺ ដេកតែនៅលើកន្ទេល ក៏ត្រូវរដ្ឋអំណាចខ្មែរក្រហមបញ្ជាឲ្យឈ្លបមកសែងគាត់យកទៅសម្លាប់ដែរ ។

មីងគ្រិន បានឲ្យដឹងថា «ការដែលមានសាលាក្តីដើម្បីជំនុំជម្រះទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនេះវាគ្រាន់តែធ្វើឲ្យខ្ញុំរំសាយចិត្តបានខ្លះប៉ុណ្ណោះ មិនអាចធ្វើឲ្យខ្ញុំបំភ្លេចនូវការឈឺចាប់ដែលខ្មែរក្រហមបានបំផ្លាញអស់នូវសុភមង្គលដែលគ្រួសារខ្ញុំធ្លាប់មានពីមុនមកឡើយ» ។ មីងគ្រិន បានបន្ថែមទៀតថា «ក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះខ្ញុំមើលថែទាំកូនតូចៗទាំង៣នាក់ផង និងត្រូវប្រឈមមុខនឹងជីវភាពប្រចាំថ្ងៃផង» ។

អ្វីដែលដែល មីងគ្រិន និងអ្នកភូមិព្រះឱង្ការបានបាត់បង់ទៅ មិនមានអ្វីអាចមកបំពេញឲ្យគ្រប់បានឡើយ មានតែសាលាក្តីដើម្បីជំនុំជម្រះទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមតែមួយគត់ដែលអាចជួយឲ្យ មីងគ្រិន និងអ្នកភូមិព្រះឱង្ការ រសាយពីការឈឺចាប់ និងទទួលយកការផ្សះផ្សាជាតិមួយបាន ។

ឡុង ដានី

## ពន្យល់ពាក្យខ្មែរក្រហម

◆ **គោលជំហរមោទនភាព:** គឺជាគោលជំហរពេញចិត្តពេញថ្លើម ស្រឡាញ់ចង់បានរបស់អ្វីមួយ ពេញចិត្តពេញថ្លើមនឹងប្រព្រឹត្តអំពើអ្វីមួយ ។

(យុវជន-យុវនារីបដិវត្ត លេខពិសេសខែសីហា-កញ្ញា ១៩៧៤)

◆ **ប្រតិកិរិយា:** ការចម្រើនថយក្រោយហួសសម័យ ប្រាសជើង ។

◆ **ប្រត្តិបត្តិ:** ការអនុវត្តតាម ធ្វើតាមលុះដោយសុឆន្ទៈ ។

◆ **ប្រតិកម្ម:** ធ្វើឲ្យមានសកម្មភាព ។

◆ **ប្រតិសកម្ម:** សកម្មភាពដែលមានដំណើរទៅមុខ និងដំណើរកំពុងអនុវត្ត ។

(កំណត់ហេតុរបស់សមមិត្ត អ៊ីវ ពេជ្រ)

◆ **និន្នាការ:** លម្អៀងទៅតាមគេគ្មានសេចក្តីផ្តើមគំនិតខ្លួនឯង ។

(កំណត់ហេតុលេខ ១០)

នេះជាចុងបញ្ចប់នៃវគ្គទី៥ នៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌកឯកសារកម្ពុជា ដែលនិយាយពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងការផ្សាយនៃវគ្គបន្ទាប់ យើងខ្ញុំនឹងពិភាក្សាអំពីប្រធានបទនៃឧក្រិដ្ឋកម្មសង្គ្រាម ហើយនឹងស្វែងយល់ ថាតើឧក្រិដ្ឋសង្គ្រាមអាចឆ្លុះបញ្ចាំងនៅក្នុងបរិបទនៃការអត់ឃ្លានបានដែរឬទេ ដោយលើកយកការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមមកធ្វើការពិភាក្សា ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ដែលបានតាមដានស្តាប់ការផ្សាយរបស់យើងខ្ញុំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស៊ីឌីយោថតសម្លេង ។

ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗនៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើរមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។ សូមអរគុណ ។

កម្មវិធីវិទ្យុនេះឧបត្ថម្ភដោយ នាយកដ្ឋានកម្មវិធីសកលនៃការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលកម្ម របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

កម្មវិធីវិទ្យុនេះ ចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ វិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង៨ព្រឹក និង ម៉ោង៤រសៀល ។